# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
លេខ :

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់ថ្លៃឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានសំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

## សម្រេច

**ប្រការ ១.-**

រូបវ័ន្តបុគ្គល ឬនីតិបុគ្គលមុននឹងទទួលបានអាជ្ញាប័ណ្ណធនធានរ៉ែពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវបង់ជូនរដ្ឋនូវថ្លៃឈ្នួលដីប្រចាំឆ្នាំជាមុនសំរាប់ឆ្នាំដំបូង ក្នុងកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បានចេញអាជ្ញាប័ណ្ណធនធានរ៉ែឱ្យទៅរូបវ័ន្តបុគ្គល ឬនីតិបុគ្គលនោះ ។ សំរាប់ការបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំបន្តបន្ទាប់ សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវថ្លៃឈ្នួលដីប្រចាំឆ្នាំក្រោមសុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែនោះ ក្នុងកំឡុងខែទីមួយនៃឆ្នាំប្រតិទិន។

**ប្រការ ២.-**

ថ្លៃឈ្នួលដីប្រចាំឆ្នាំ ត្រូវបង់នៅធនាគារជាតិឬសាខាធនាគារខេត្ត-ក្រុង ដែលតំបន់សម្បទាននោះស្ថិតនៅ។

**ប្រការ ៣.-**

ថ្លៃឈ្នួលដីប្រចាំឆ្នាំ ដែលត្រូវបង់ ត្រូវគណនាតាមទំហំផ្ទៃក្រឡានៃតំបន់សម្បទានសំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែដែលបានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែនោះ ។

**ប្រការ ៤.-**

ថ្លៃឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានសំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែត្រូវបានកំណត់តាមអាត្រាដូចខាងក្រោម:

| ប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែ | ថ្លៃឈ្នួលដីប្រចាំឆ្នាំ |
|---|---|
| ១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | |
| -ប្រភេទ ក (សំរាប់រ៉ែរបេះដាច់ ខ្សាច់ ក្រួស ឡាតេរីត) | ១០ (ដប់) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ ខ (សំរាប់រ៉ែមាស) | ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |

| | |
|---|---|
| -ប្រភេទ គ (សំរាប់រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ) | ៣០ (សាមសិប)ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| ២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម | |
| -ប្រភេទ ក (សំរាប់ថ្មអារ និងថ្មបំបែក) | ៤០ (សែសិប) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ ខ (សំរាប់រ៉ែរបេះដាច់ ខ្សាច់ គ្រួស ឡាតេរីត) | ២០ (ម្ភៃ) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ គ (សំរាប់ថ្មកំបោរ) | ១០ (ដប់) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| ៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | |
| -ប្រភេទ ក (សំរាប់រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ) | ១២ (ដប់ពីរ) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ ខ (សំរាប់ថ្មសំអាង) | ៤០ (សែសិប) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| ៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ | ថ្លៃឈ្នួលដីឬទីតាំងអនុវត្តតាមច្បាប់សារពើពន្ធ |
| ៥- អាជ្ញាប័ណ្ណស្វែងរុករក | |
| - ពីឆ្នាំទី១ ដល់ឆ្នាំទី២ | ០.១៥ (ដប់ប្រាំសេន)ដុល្លារអាមេរិក /ហិកតា/ឆ្នាំ |
| - ពីឆ្នាំទី៣ ដល់ឆ្នាំទី៤ | ០.៣០ (សាមសិបសេន) ដុល្លារអាមេរិក /ហិកតា/ឆ្នាំ |
| - ចាប់ពីឆ្នាំទី៥ឡើងទៅ | ០.៥០ (ហាសិបសេន)ដុល្លារអាមេរិក /ហិកតា/ឆ្នាំ |
| ៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ | |
| - ពីឆ្នាំទី១ ដល់ឆ្នាំទី៣ | ៤ (បួន) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| - ពីឆ្នាំទី៤ ដល់ឆ្នាំទី៥ | ៨ (ប្រាំបី) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| - ពីឆ្នាំទី៦ ឡើងទៅ | ១០ (ដប់) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |

## ប្រការ ៥.-

នៅរៀងរាល់ត្រីមាស និងដំណាច់ឆ្នាំនីមួយៗ អគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុងត្រូវរាយការណ៍អំពីចំណូលឈ្នួលដីប្រចាំឆ្នាំជាពីរ(០២)ច្បាប់ ដោយមួយច្បាប់ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) និងមួយច្បាប់ទៀតផ្ញើមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ) ដោយត្រូវភ្ជាប់មកជាមួយនូវសលាកប័ត្រចំណូលថវិកាជាតិ ។

## ប្រការ ៦.-

រាល់ថ្លៃឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែទាំងអស់ ឬវត្ថុធាតុដើមថ្មសំភារៈសំណង់រវាងក្រសួងឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលជាមួយនិងក្រុមហ៊ុន ឬអាជីវករដែលមានពីមុន ហើយផ្ទុយនឹងប្រកាសនេះ ត្រូវកែសម្រួលឱ្យស្របទៅតាមប្រកាសនេះ ។

ប្រការ ៧.-

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងរូបវ័ន្តបុគ្គល នីតិបុគ្គល និងសម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៨.-

ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

កន្លែងទទួល :

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ខេត្ត-ក្រុង (ដើម្បីជូនជ្រាប)
- ដូចប្រការ ៧ (ដើម្បីអនុវត្ត)
- កាលប្បវត្តិ-ឯកសារ